# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ អញ្ជើញជាអធិបតី ក្នុងពិធីប្រកាស
# តែងតាំងមុខតំណែងប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត ព្រះសីហនុ








នៅរសៀលថ្ងៃទី២២ ខែ មីនា ឆ្នាំ២០១៤ នៅសាលាខេត្តកំពត មានរៀបចំពិធីប្រកាសតែងតាំងមុខតំណែងប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តព្រះសីហនុ ក្រោមអធិបតីភាព ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយមានការចូលរួម ពីឯកឧត្តម **សុខ ផន** អភិបាលរងខេត្តព្រះសីហនុ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញក្រោមឪវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម តំណាងអាជ្ញាធរខេត្ត តំណាងមន្ទីរ អង្គភាពជុំវិញខេត្ត និងមន្ត្រីរាជការនៃមន្ទីរឧស្សាហកម្មខេត្ត ជាច្រើនរូបទៀត ។

តាមរបាយការណ៍សង្ខេបពីតំណាងមន្ទីរឧស្សាហកម្មនិងសិប្បកម្មខេត្តព្រះសីហនុ បានបញ្ជាក់ថាៈមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះសីហនុ មានមន្ត្រីរាជការ បុគ្គលិកកម្មករ ចំនួន៥៥ នាក់ ស្រី០៣នាក់ ចែកចេញជាពីរផ្នែកៈ**ទី១-** នៅថ្នាក់មន្ទីរមានមន្ត្រីសរុបចំនួន ០៨នាក់ **ទី២-**អង្គភាពរដ្ឋាករទឹកមានមន្ត្រីរាជការ បុគ្គលិក កម្មករ ចំនួន៤៧ នាក់។ ក្នុងនោះមានមន្ត្រីរាជការចំនួន១១នាក់ និង៣៦ នាក់ទៀត ជាបុគ្គលិក កម្មករក្រៅក្របខ័ណ្ឌ មានថ្នាក់ដឹកនាំចំនួន០៣រូប គឺប្រធាន ០១រូប និងអនុប្រធាន០២រូប ។ អំពីការងារទឹកស្អាត គឺអង្គភាពរដ្ឋាករទឹកខេត្ត ស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរឧស្សាហកម្ម និងសិប្បកម្ម អាចផ្គត់ផ្គង់ទឹកជូនដល់ប្រជាពលរដ្ឋក្នុងក្រុងព្រះសីហនុ បានចំនួន៧០% ដែលមានអតិថិជនសរុប ៧១៥០ ។រីឯ ប្រភពទឹករបស់អង្គភាពរដ្ឋាករទឹក គឺ ៈបឹងព្រែកទប់ ទំហំ ១៥ ហិចតា អាចស្តុកទឹកបាន ៥០០.០០០ ម៉ែត្រគូប។ ប៉ុន្តែ តែងតែរីងស្ងួតនៅចុងខែមីនា ធ្វើឱ្យមានការខ្វះខាតទឹក ។ ចំពោះការផ្គត់ផ្គង់ និងតម្រូវការទឹកគឺ តម្រូវការទឹក ក្នុងរដូវវស្សា ៩.០០០ ម៉ែត្រគូប ក្នុងមួយថ្ងៃ និងតម្រូវការទឹកក្នុងខែប្រាំង ១៣.០០០ ម៉ែត្រគូប ក្នុងមួយថ្ងៃ។ អង្គភាពផលិតទឹកស្អាតផ្ទាល់ខ្លួនពីបឹងព្រែកទប់ប្រមាណ២០% ។ក្រៅពីនោះទិញពីក្រុមហ៊ុន Anco Water Supply Co.Ltd ។ ដោយឡែកក្រុមហ៊ុន Anco Water Supply Co.Ltd បានទទួលសិទ្ធិពីអតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យធ្វើផលិតកម្មទឹកស្អាតលក់ដុំឱ្យអង្គភាពរដ្ឋាករទឹកខេត្ត តាមតម្រូវការ ក្នុងតម្លៃ ១.០០០រៀល ក្នុងមួយម៉ែត្រគូប ។ បច្ចុប្បន្នក្រុម

ហ៊ុនមានសមត្ថភាពអាចផលិតទឹកស្អាតបាន ២៥.០០០ ម៉ែត្រគូប ក្នុងមួយថ្ងៃ ដោយផ្គត់ផ្គង់ឱ្យរដ្ឋាករទឹកខេត្ត តំបន់សេដ្ឋកិច្ចពិសេសបត់ត្រង់ រោងចក្រអគ្គិសនី ដុតត្បូងថ្ម និងអតិថិជនតាមផ្ទះមួយចំនួនទៀត ។ អំពីការងារឧស្សាហកម្ម ខេត្តព្រះសីហនុមានរោងចក្រចំនួន៦២ រួមមានៈរោងចក្រកាត់ដេរសំលៀកបំពាក់ចំនួន២៩ រោងចក្រផលិតស្បែកជើងចំនួន០៩ រោងចក្រផលិតភេសជ្ជៈចំនួន០១ និងរោងចក្រផ្សេងៗទៀត ចំនួន២៣ ។ ចំពោះការងារសិប្បកម្ម ខេត្តព្រះសីហនុមានមូលដ្ឋានសិប្បកម្មចំនួន ២១៥ រួមមានសិប្បកម្មផលិតចំណីអាហារ កែច្នៃ វេចខ្ចប់ និងផលិតផលផ្សេងៗទៀត ។ ការងារស្តង់ដារ មន្ទីរឧស្សាហកម្ម និងសិប្បកម្ម បានយកចិត្តទុកដាក់ជម្រុញដល់បណ្តារោងចក្រសិប្បកម្មទាំងអស់ ត្រូវយកមុខផលិតផលរបស់ខ្លួនទៅវិភាគពិនិត្យគុណភាព ឱ្យបានទៀងទាត់តាមច្បាប់ស្តង់ដារកម្ពុជា ។ ទាក់ទងការងារមាត្រាសាស្ត្រ មន្ទីរខានសហការជាមួយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិកម្ពុជា ធ្វើសម្រង់ស្ថិតិ ធ្វើបច្ចុប្បន្នភាពឧបករណ៍មាត្រាសាស្ត្រ ហើយបានត្រួតពិនិត្យលើកដំបូង ត្រួតពិនិត្យសារឡើងវិញ ត្រួតពិនិត្យធ្នក់ លើឧបករណ៍មាត្រសាស្ត្រគ្រប់ប្រភេទតាមគោលការណ៍ណែនាំរបស់ក្រសួង ។



បន្ទាប់ពីឯកឧត្តម **អ៊ុំ សុថា** នាយកខុទ្ទកាល័យនិងជាអគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានអានប្រកាសលេខៈ០៩៨ MIH/2014 ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ដែលបានសម្រេចតែងតាំងលោក **ប្រាក់ ប្រាកដ** ជាប្រធានមន្ទីរឧស្សាហកម្ម និង សិប្បកម្ម ខេត្តព្រះសីហនុ រួចមក លោក **ប្រាក់ ប្រាកដ** បានឡើងទទួលសេចក្តីប្រកាស ស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ពីឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ព្រមទាំងបានធ្វើការប្តេជ្ញាចិត្តយ៉ាងមុតមាំ ដើម្បីឆ្លើយតប និងការផ្តល់ទំនុកចិត្ត របស់ឯកឧត្តម ទេសរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម គណៈអភិបាលខេត្ត និង ក្រុមប្រឹក្សាខេត្ត

ដោយបានសន្យា ថា:នឹងខិតខំប្រមូលនូវកម្លាំងកាយ បញ្ញា ស្មារតី និងបទពិសោធន៍ ដែលមានកន្លងមក ធ្វើជាមូលដ្ឋានក្នុងការសម្របសម្រួល ចាត់ចែងការងារមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានល្អប្រសើរ ។

ឯកឧត្តម **សុខ ផន** អភិបាលរងខេត្តព្រះសីហនុ បានឡើងសំដែងការស្វាគមន៍និងអបអរសាទរចំពោះលោក **ប្រាក់ ប្រាកដ** ដែលត្រូវបានតែតាំងជាប្រធានមន្ទីរថ្មីនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ព្រមទាំងបានលើកឡើង ពីស្ថានភាពទូទៅរបស់ខេត្តទាក់ទងការងារអភិវឌ្ឍន៍ និងកិច្ចការពារសណ្តាប់ធ្នាប់សាធារណៈ សំដៅបម្រើភាពសុខសាន្ត របស់ប្រជាពលរដ្ឋមូលដ្ឋាន ក៏ដូចជាភ្ញៀវទេសចរណ៍ ជាតិ អន្តរជាតិ ។ ឯកឧត្តម **សុខ ផន** បានសម្តែងនូវក្តីសង្ឃឹមថា: លោកប្រធានមន្ទីរ នឹងបន្តនូវស្មារតីខិតខំប្រឹងប្រែង បំពេញការងាររបស់ខ្លួន ក្នុងតួនាទីភារកិច្ចថ្មី ក្នុងបរិបទនៃបទពិសោធន៍ដែលមានស្រាប់ ហើយត្រូវប្រមូលផ្តុំនូវកំលាំងសាមគ្គីភាព ឯកភាពផ្ទៃក្នុង ដែលជាមូលដ្ឋាននៃភាពជោគជ័យ លើគ្រប់ការងារទាំងអស់ ដោយត្រូវបន្តរក្សានូវរាល់ការទំនាក់ទំនងល្អ ជាមួយមន្ទីរ និងស្ថាប័នពាក់ព័ន្ធដ៏ទៃទៀត ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងត្រូវផ្អែកលើនីតិសម្បទាគតិយុត្តិ ផែនការយុទ្ធសាស្តអភិវឌ្ឍន៍ជាតិ កម្មវិធីនយោបាយរបស់សាម៉ីស្ថាប័ន ផែនការអភិវឌ្ឍន៍ខេត្ត យុទ្ធសាស្រ្តចតុកោណ និងស្ថាប័នជាក់ស្តែងរបស់ខេត្ត ដើម្បីជាមូលដ្ឋាននៃការកសាងនូវផែនការ និងកម្មវិធីការងាររបស់មន្ទីរខ្លួនប្រកបដោយសង្គតភាព ។



ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានអញ្ជើញមានមតិសំណេះសំណាល ដោយបាន សំដែងនូវការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែង និងការដឹកនាំរបស់អជ្ញាធរខេត្តគ្រប់លំដាប់ថ្នាក់ ធ្វើឱ្យខេត្តព្រះសីហនុមាន ការរីកចម្រើនប្រែមុខមាត់ថ្មីសមជាខេត្តទេសចរណ៍ ដែលមានមាត់សមុទ្រ ឆ្នេរខ្សាច់ កោះ និងព្រៃភ្នំដ៏ស្រស់ត្រកាល។ ឯកឧត្តម បានអបអរសាទរចំពោះលោក **ប្រាក់ ប្រាកដ** ដែលត្រូវបានប្រគល់ភារកិច្ចថ្មី ជាប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម

ខេត្តព្រះសីហនុ ដោយលោក គឺជាមន្ត្រី នៅទីនេះស្រាប់ មានបទពិសោធន៍យូរឆ្នាំ សង្ឃឹមថាៈកិច្ចការគ្រប់គ្រង ដឹកនាំមន្ទីរមានដំណើរការកាន់តែល្អប្រសើរ និងមាន ភាពរលូនទៅមុខ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថាៈថ្វីត្បិតតែក្រសួងឧស្សាហកម្ម និង សិប្បកម្ម បង្កើតឡើងនៅ លើមូលដ្ឋាននៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលជាក្រសួងចាស់ស្រាប់ ប៉ុន្តែតម្រូវឱ្យមានការរៀបចំជាថ្មីនូវច្បាប់ អនុក្រឹត្យ ដែលកំណត់ឡើងវិញនូវមុខងារ ភារកិច្ច បេសកកម្ម ព្រមទាំង ចាំបាច់ត្រូវកែសម្រួលរចនាសម្ព័ន្ធឡើងវិញដែរ (រាប់ទាំងឈ្មោះមន្ទីរ និងត្រាមូល) ។ ដូច្នេះ ត្រូវមានការតែងតាំងជាថ្មី មានលក្ខណៈ ព្រម១គ្នានូវប្រធានមន្ទីរគ្រប់ខេត្ត ទូទាំងប្រទេសសម្រាប់អណត្តិការងារថ្មីនេះ ។ ទន្ទឹមនឹងរៀបចំតួនាទី ភារកិច្ចរបស់ នាយកដ្ឋាននានា ក្រសួងកំពុងរៀបចំ ប្រកាសថ្មីសម្រាប់ដំណើរការការងាររបស់មន្ទីរ ដោយគ្រោងឱ្យមាន ការិយាល័យ ចំនួន០៤ ចំណុះមន្ទីរគឺៈ**១**-ការិយាល័យ កិច្ចការទូទៅ **២**-ការិយាល័យកិច្ចការឧស្សាហកម្ម **៣**-ការិយាល័យ ស្តង់ដារ និងមាត្រាសាស្ត្រ និង **៤**-ការិយាល័យ ទឹកស្អាត ។ ទាក់ទង និងការយាល័យជំនាញខាងលើ ដូចជាៈ ការិយាល័យ ស្តង់ដារ និងមាត្រាសាស្ត្រ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានរំលឹកថាៈការិយាល័យនេះ ត្រូវមានកិច្ចការងារច្រើនក្នុងការចុះត្រួតពិនិត្យនូវឧបករណ៏រង្វាស់រង្វាល់ ដូចជាៈកុងទ័រទឹក-ជញ្ជីញថ្លឹង-ពិនិត្យសុក្រឹតភាពនៃចំណុះប្រេងសាំងតាមស្ថានីយ៏ប្រេង នានា និងពិនិត្យការគោរពស្តង់ដាម្ហូបអាហារជាដើម ។ ជាមួយគ្នានេះ ការិយាល័យឧស្សាហកម្ម ក៏មានភារកិច្ចការចុះពិនិត្យ ជាក់ស្តែងដល់ទីតាំងរោងចក្រ និងការចុះបញ្ជីឱ្យអស់នូវសហគ្រាសខ្នាតតូច និងមធ្យម ដែលមានរហូតដល់២១៥មូលដ្ឋានក្នុងខេត្ត ដើម្បីឱ្យសហគ្រិនទាំងអស់នោះ ក្លាយជានីតិបុគ្គល និងងាយស្រួល ក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៏ ។ ដោយ ឡែកទាក់ទង និងការងារទឹកស្អាត ឯកឧត្តម ទេសរដ្ឋមន្ត្រីបានបញ្ជាក់ថាៈខេត្តព្រះសីហនុ ជាខេត្តទេសចរណ៏ដ៏សំខាន់ ការផ្គត់ផ្គង់ទឹកស្អាតជាការចាំបាច់បំផុត ។ ដូច្នេះ យើងត្រូវរិះរកគ្រប់មធ្យោបាយ ជាពិសេសសហការជាមួយដៃគូឯកជន ដើម្បីធ្វើយ៉ាងណា ឱ្យការផ្គត់ផ្គង់ទឹកស្អាតក្នុងខេត្តអនុវត្តបាននូវគោលការណ៏០៤ យ៉ាងគឺៈ គុណភាព-សុវត្ថិភាព-និរន្តរភាព និងតម្លៃសមរម្យ ។



គួរបញ្ជាក់ថា៖នៅមុន និងក្រោយការប្រារព្ធពិធីប្រកាសតែងតាំងប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** តំណាងអាជ្ញាធរខេត្ត និងប្រតិភូអមដំណើរ បានអញ្ជើញចុះពិនិត្យជាក់ស្តែងទីតាំងបឹងព្រែកទប់ ដែលមានទំហំ ១៥ ហិចតាក្នុងទីរួមខេត្ត ពិនិត្យអង្គភាពរដ្ឋាករទឹកខេត្តដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តព្រះសីហនុ ជួបសំណេះសំណាលជាមួយមន្ត្រី នៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តព្រះស៊ីហនុ និងឧបត្ថម្ភថវិការមួយចំនួន ព្រមទាំងអញ្ជើញចុះត្រួតពិនិត្យផលិតកម្មទឹកស្អាត និងអាងស្តុកទឹករបស់ក្រុមហ៊ុន Anco Water Supply Co.Ltd ដែលស្ថិតក្នុងតំបន់រម្មណីយដ្ឋានក្បាលឆាយ ខេត្តព្រះសីហនុ មុននឹងបន្តដំណើរវិលត្រឡប់មករាជធានីភ្នំពេញវិញ ។

















